**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប**
**ASIA EURO UNIVERSITY**
លេខ: ០៦៩/១០ សអអ/គណាន

# គោលការណ៍ណែនាំស្ដីពី
# នីតិវិធីស្នើសុំបន្តការសិក្សា និង ការពារនិក្ខេបបទបណ្ឌិត
# នៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

**យោង ៖**

-អនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៥ ស្ដីពីការទទួលស្គាល់ការប្រែក្លាយពីវិទ្យាស្ថាន អាស៊ី អឺរ៉ុប ទៅជាសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

-ប្រកាសលេខ២០៨៥ អយក.ប្រក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិតជាភាសាជាតិនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប របស់ក្រសួងអប់រំ យុវជន និងកីឡា

-សេចក្ដីសម្រេចលេខ ០០៣/០៩ សអអ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩ ស្ដីពី គោលការណ៍បណ្ដុះបណ្ដាលបណ្ឌិត របស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

-សេចក្ដីសម្រេចលេខ ២០៦.ស/សអអ/សសរ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១១ ស្ដីពីក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រ របស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

-តាមតម្រូវការចាំបាច់នៃការបណ្ដុះបណ្ដាលថ្នាក់បណ្ឌិត

និស្សិតបណ្ឌិតដែលកំពុងសិក្សានៅតាមគ្រឹះស្ថានសិក្សានានា ដែលមានបំណងបន្តការសិក្សា និង/ឬ ការពារនិក្ខេបបទបណ្ឌិតនៅសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ត្រូវអនុវត្តតាមការណែនាំដូចខាងក្រោម៖

## ១-ការដាក់ឯកសារស្នើសុំ

-និស្សិតបណ្ឌិតត្រូវដាក់លិខិតស្នើសុំដោយបញ្ជាក់ពីកម្មវត្ថុឱ្យបានច្បាស់

-ការភ្ជាប់សំណុំឯកសារ មានដូចជា ៖

| | |
|---|---|
| -ព្រឹត្តិប័ត្រពិន្ទុសិក្សាមុខវិជ្ជាអប្បបរមាចំនួន | ០១ច្បាប់ |
| -និក្ខេបបទដែលបានការពារសាកល្បងចំនួន | ០២ច្បាប់ |
| -អត្ថបទចុះផ្សាយទស្សនាវដ្ដីវិទ្យាសាស្ត្រចំនួន | ០២អត្ថបទ(២លើក) |
| -សំណុំឯកសារពាក់ព័ន្ធដ៏ទៃទៀត ។ | |

## ២-ការពិនិត្យនិងសម្រេច

-ការប្រជុំសម្រេចរបស់ក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រ។

-ការសម្រេចរបស់ក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រមានដូចជា អនុញ្ញាតឱ្យសិក្សាបន្ថែមលើមុខវិជ្ជាមួយចំនួន ឬ

អនុញ្ញាតឱ្យការពារនិក្ខេបបទបណ្តោះអាសន្ន ឬ អនុញ្ញាតឱ្យការពារនិក្ខេបបទថ្នាក់ជាតិ ជាដើម អាស្រ័យទៅតាមសំណុំឯកសាររបស់សាមីនិស្សិត។

-ការធ្វើរបាយការណ៍និងនីតិវិធីបន្តទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីទទួលស្គាល់សាមីនិស្សិតជាផ្លូវការ និង/ឬ សុំរៀបចំអនុម័តគណៈកម្មការការពារនិក្ខេបបទថ្នាក់ជាតិ ។ល។

**៣-ការបង់ថ្លៃសិក្សា**

-ការបង់ថ្លៃសិក្សា អាស្រ័យលើលទ្ធផលនៃការសម្រេចរបស់ក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រ។

-ក្នុងករណីក្រុមប្រឹក្សាបណ្ឌិតសភាវិទ្យាសាស្ត្រសម្រេចអនុញ្ញាតឱ្យការពារថ្នាក់ជាតិ បេក្ខជនបណ្ឌិតត្រូវបង់ថ្លៃសិក្សាចំនួន០១ឆ្នាំ( ឆ្នាំទី៣ ) និង សេវារដ្ឋបាល។ ឯការចំណាយផ្សេងទៀត ជាបន្ទុករបស់សាមីនិស្សិត។

-លើកលែងតែមានគោលការណ៍ការណែនាំផ្សេងទៀត។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១១

**សាកលវិទ្យាធិការ**

**ឡុង_លាង**